សភ
MUSALVY

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ១០០ សកបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០០២

Prakas # 100 (MOSALVY)
on Suspension of Weekly Day off
(April 11, 2002)

# ប្រកាស
## ស្តីពី
## ការព្យួរការសំរាកប្រចាំសប្តាហ៍

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## <u>សំរេច</u>

<u>ប្រការ១</u>.- ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ អាចព្យួរការឈប់សំរាកប្រចាំសប្តាហ៍របស់កម្មករនិយោជិតបាន ក្នុងករណីដូចមានចែងក្នុងមាត្រា ១៥១ នៃច្បាប់ស្តីពីការងារ ។

<u>ប្រការ២</u>.- នៅក្នុងសហគ្រាស គ្រឹះស្ថានខ្លះ និយោជកអាចកាត់បន្ថយការឈប់សំរាកប្រចាំសប្តាហ៍របស់កម្មករនិយោជិតចំនួន ២ថ្ងៃក្នុងមួយខែ ដើម្បីទូទាត់ថ្ងៃធ្វើការមិនកើតកន្លងទៅ ដែលបណ្តាលមកពីអាកាសធាតុមិនល្អ។ សហគ្រាស គ្រឹះស្ថានប្រភេទនេះ មានដូចតទៅ:-

-សហគ្រាស គ្រឹះស្ថានបំរើការងារសាធារណៈដូចជា ការងារបោសសំអាត ឬប្រមូលសំរាមនៅតាម

K

ផ្ទាំ ទីលានសាធារណៈ ការងារជួសជុល ធ្វើថ្នាំ ឬរទ្វីក

-សហគ្រាស គ្រឹះស្ថានបំរើការងារជួសជុល ឬតបំពង់ទឹក ឬបំពង់ឧស្ម័ន ជួសជុល ឬប្រក់ដំបូលផ្ទះ ឬអគារ

-សហគ្រាស គ្រឹះស្ថានសំណង់ ចំពោះការងារដែលប្រព្រឹត្តទៅនៅផ្នែកខាងក្រៅនៃអគារ

-សហគ្រាស គ្រឹះស្ថានឡជង្គ ចំពោះការងារដែលប្រព្រឹត្តទៅនៅកណ្តាលវាល

-សហគ្រាស គ្រឹះស្ថានកាយយករ៉ែ ចំពោះការងារដែលប្រព្រឹត្តទៅនៅកណ្តាលវាល

-សហគ្រាស គ្រឹះស្ថានដឹកជញ្ជូនតាមផ្លូវទឹក

-ភោជនីយដ្ឋាន និងកន្លែងលក់ដូរដែលប្រព្រឹត្តទៅនៅកណ្តាលវាល

-សហគ្រាស គ្រឹះស្ថាន បេះ ឬប្រមូលផ្លែឈើ ឬបន្លែ

-សហគ្រាស គ្រឹះស្ថាន ចិញ្ចឹមសត្វសន្ទានខ្យង ខ្ចៅ ឬត្រី

-សហគ្រាស គ្រឹះស្ថាន ផលិតទឹកត្រី ឬអំបិល

-សហគ្រាស គ្រឹះស្ថាន ធ្វើប្រេកកំប៉ុងទូវផ្លែឈើ បន្លែ ឬត្រី

-សហគ្រាស គ្រឹះស្ថាន លើកដាក់ផលិតផល ឬវត្ថុធាតុដែលឆាប់ខូច

-សហគ្រាស គ្រឹះស្ថានកសិកម្ម និងនេសាទ។

ការធ្វើការសងនៅថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ចំពោះប្រភេទសហគ្រាស គ្រឹះស្ថាន ដូចបានរៀបរាប់ខាងលើ ត្រូវអនុវត្តក្នុងខែបន្ទាប់ពីថ្ងៃធ្វើការមិនកើតដោយអាកាសធាតុមិនល្អ។ ករណើត្រូវធ្វើការសងពីរថ្ងៃ ថ្ងៃទាំងពីរនេះមិនត្រូវជាថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ពីរដែលជាប់គ្នាឡើយ។

ប្រការ៣.- ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដទៃទៀតក៏អាចព្យួរការឈប់សំរាកប្រចាំសប្តាហ៍របស់កម្មករនិយោជិតបានដែរ។ ការព្យួរនេះ បើមានចំនួន ២ថ្ងៃក្នុងមួយខែ មិនត្រូវជាថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ពីរដែលជាប់គ្នាឡើយ។

ប្រការ៤.- នៅមុនពេលដាក់អោយកម្មករនិយោជិតធ្វើការនៅថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ដូចមានចែងក្នុងប្រការ១ ប្រការ២ ប្រការ៣ខាងលើ និយោជកត្រូវស្នើសុំសេចក្តីអនុញ្ញាតពីអធិការការងារ ដោយបញ្ជាក់ពីមូលហេតុនៃការព្យួរការឈប់សំរាកប្រចាំសប្តាហ៍នេះ កាលបរិច្ឆេទ និងថិរវេលានៃការព្យួរ ចំនួនកម្មករនិយោជិតដែលមិនបានឈប់សំរាក ព្រមទាំងបែបបទនៃការឈប់សំរាកសងដោយទូទាត់វិញក្នុងរយៈពេល ៣០ថ្ងៃ។ អធិការការងារត្រូវជូនដំណឹងដល់ និយោជក ដែលសុំការអនុញ្ញាតនោះ អំពីការសំរេចរបស់ខ្លួនក្នុងរយៈពេល ៤ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។បើមិនដូច្នេះទេពាក្យសុំការអនុញ្ញាត និងត្រូវចាត់ទុកថាបានយល់ព្រមហើយ។

ប្រការ៥.- កម្មករ និយោជិតដែលធ្វើការនៅថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ត្រូវបានប្រាក់ឈ្នួលស្មើ និងពីរដងនៃប្រាក់

ឈ្នួលថ្ងៃធ្វើការធម្មតា ។

<u>ប្រការ៦</u>.- ក្នុងករណីប្រធានស័ក្តិ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អាចព្យួរការឈប់សំរាកប្រចាំសប្តាហ៍របស់កម្មករនិយោជិត ដោយពុំចាំបាច់ស្នើសុំការអនុញ្ញាតជាមុនពីអធិការការងារឡើយ ។

<u>ប្រការ៧</u>.- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៩១ សកអ. ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៨ និងលេខ២០៩ សកអ. ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>ប្រការ៨</u>.- ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៕

<u>ចម្លងជូន</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

"ដើម្បីជ្រាប"

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- កាលប្បវត្តិ និងឯកសារ

អ៊ិត សំហេង